# របាយការណ៍លទ្ធផលការងារឆ្នាំ ២០២២
# និងលើកទិសដៅការងារឆ្នាំ២០២៣ របស់ ក្រសួងអភិវឌ្ឍន៍ជនបទ
# និងមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តកំពង់ចាម

## សេចក្តីផ្តើម

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម មានទីតាំងស្ថិតនៅភូមិទី៧ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាម ដោយមានមន្ត្រីរាជការបម្រើការងារជាប្រចាំចំនួន ៤១នាក់ ស្រី ១២នាក់ ក្នុងនោះរួមមាន ប្រធានមន្ទីរ ០១នាក់ អនុប្រធានមន្ទីរ០៧នាក់ និងមន្ត្រីចំនួន ៣២នាក់ មានការិយាល័យជំនាញចំនួន ១០ការិយាល័យ និងមានមន្ត្រីជាប់កិច្ចសន្យាចំនួន ០១នាក់ ស្រី ០១នាក់ ហើយបានយកចិត្តទុកដាក់អនុវត្តការងារដោយធ្វើការសហការគ្នាបានយ៉ាងល្អគ្រប់លំដាប់ថ្នាក់ជាពិសេសជាមួយមូលដ្ឋានក្រុង / ស្រុក ឃុំ /សង្កាត់ បំពេញតាមតួនាទី ទស្សនវិស័យ និងគោលនយោបាយ ដើម្បីសម្រេចគម្រោងផែនការសកម្មភាពប្រចាំឆ្នាំ។

## I. សមិទ្ធផលសម្រេចបាន

### ១.ការពង្រឹងស្ថាប័ន និងកសាងសមត្ថភាព

- **ការងាររដ្ឋបាល និងបុគ្គលិក**

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម មន្ត្រីសរុបចំនួន៤០នាក់ ស្ត្រី១១នាក់ និងមានមន្ត្រីជាប់កិច្ចសន្យាចំនួន ០១នាក់ ស្រី ០១នាក់ ក្នុងនោះរួមមានប្រធានមន្ទីរ ០១នាក់ និងអនុប្រធានមន្ទីរ ០៧នាក់។ មន្ទីរបានទទួលលិខិតចូលចំនួន ៥៦០ច្បាប់ និងបានចុះលេខលិខិតចេញ ៤៥៤ច្បាប់។ មន្ទីរបានផ្សព្វផ្សាយជូនមន្ត្រីរាជការ នូវគោលនយោបាយ សារាចរ សេចក្តីសម្រេច សេចក្តីណែនាំនានារបស់រាជរដ្ឋាភិបាល ក្រសួងអភិវឌ្ឍន៍ជនបទ និងរដ្ឋបាលខេត្តជាប្រចាំ ជាពិសេសវិធានការនានាទាក់ទងនឹងកិច្ចការការពារការរីករាលដាលនៃជំងឺកូវីដ១៩ ដោយប្រកាន់ខ្ជាប់នូវវិធានការរបស់ក្រសួងសុខាភិបាល **៣ កុំ ៣ ការពារ** និងមន្ត្រីរាជការទាំងអស់បានចាក់ថ្នាំវ៉ាក់សាំងការពារជំងឺកូវីដ១៩ ចំនួន ៥ដូស គ្រប់ៗគ្នា។ គ្រប់មន្ត្រីរាជការទាំងអស់មានប័ណ្ណប.ស.ស និងប័ណ្ណសំគាល់ខ្លួនមន្ត្រីរាជការ ដែលចេញដោយក្រសួងអភិវឌ្ឍន៍ជនបទ។ មន្ទីរបានបែងចែកភារកិច្ច និងការទទួលខុសត្រូវយ៉ាងច្បាស់លាស់ជូនថ្នាក់ដឹកនាំមន្ទីរ ប្រធាន អនុប្រធានការិយាល័យ និងមន្ត្រីរាជការតាមការិយាល័យនីមួយៗ។

- **ការងារផែនការ**

មន្ត្រីការិយាល័យផែនការ និងស្ថិតិបានចុះស្រង់ និងប្រមូលទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ចតាមបណ្ដាភូមិ ឃុំ / សង្កាត់ ក្រុង / ស្រុក ដើម្បីបញ្ចូលក្នុងប្រព័ន្ធតារាងទូទាំងខេត្ត។ បានរៀបចំផែនការ

អភិវឌ្ឍន៍ ៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់មន្ទីរ និងតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តគម្រោងនានា។ ចូលរួមប្រជុំត្រួតពិនិត្យវាយតម្លៃ ពិភាក្សាលើផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៣-២០២៥ និងរៀបចំគម្រោងថវិកាឆ្នាំ២០២៣ ជាមួយក្រុមការងារក្រសួងអភិវឌ្ឍន៍ជនបទ និងចូលរួមវគ្គបណ្តុះបណ្តាលការប្រមូលទិន្នន័យ សេដ្ឋកិច្ចសង្គមកិច្ចតាមបណ្តាមន្ទីរពាក់ព័ន្ធ និងតាមស្រុក ឃុំ ភូមិ ទូទាំងខេត្ត និងបញ្ចូលទិន្នន័យតាមប្រព័ន្ធអនឡាញ។ បានរៀបចំធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ របស់មន្ទីរជូនក្រុមប្រឹក្សាខេត្ត និងក្រសួងអភិវឌ្ឍន៍ជនបទ។

- **<u>ការងារផ្គត់ផ្គង់ និងហិរញ្ញវត្ថុ</u>**

ការគ្រប់គ្រងថវិការដ្ឋក្នុងឆ្នាំ២០២២ មន្ទីរទទួលបានឥណទានសរុបចំនួន **1.876.300.000 ៛** ក្នុងអនុវត្តបាន **1.681.134.110 ៛** ស្មើនឹង **89.59%** ក្នុងនោះរួមមាន៖

- ជំពូក៦០ (ការទិញ) មានឥណទានសរុប **187.200.000 ៛** អនុវត្តបាន **144.855.390 ៛** ស្មើនឹង **77.38 %** ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២។
- ជំពូក៦១ (សេវាកម្ម) មានឥណទានសរុប **865.700.000 ៛** អនុវត្តបាន **815.938.095 ៛** ស្មើ**នឹង 94.25** ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២។
- ជំពូក៦៤ (បន្ទុកបុគ្គលិក) មានឥណទានសរុប **821.700.000៛** អនុវត្តបាន **720.140.625 ៛** ស្មើនឹង **87.64 %** ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២។
- ជំពូក៦៣ (ពន្ធ និងអាករ) មានឥណទានសរុប **1.700.000 ៛** អនុវត្តបាន **200.000 ៛** ស្មើនឹង **11.76%** ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២២។

- **ការងារសវនកម្ម និងអធិការកិច្ច**

ការងារសវនកម្ម និងអធិការកិច្ចបានចុះត្រួតពិនិត្យមន្ទីរក្នុងឆ្នាំ២០២២ រួមមាន៖ សវនកម្មជាតិ សវនកម្មផ្ទៃក្នុងរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្រុមអធិការកិច្ចក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមអធិការកិច្ចក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច។

- **ការងារជនពិការ**

មន្ទីរមានមន្ត្រីដែលជាជនពិការកំពុងបម្រើការងារចំនួន ០១រូប ភេទ ប្រុស ដោយមានជំងឺសរសៃប្រសាទរ៉ាំរ៉ៃ។

- **ការងារយេនឌ័រ**

មន្ទីរមានថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាចំនួន ១២រូបជាស្ត្រី កំពុងបម្រើការងារក្នុងមន្ទីរយ៉ាងសកម្ម។ ស្ត្រីបានចូលរួមក្នុងកិច្ចប្រជុំ សិក្ខាសាលានានា ស្តីពីការងារយេនឌ័រទាំងនៅក្នុងខេត្ត និងក្រសួង និងរៀបចំដោយក្រសួងកិច្ចការនារី រួមទាំងស្ថាប័នផ្សេងៗ។ ថ្នាក់ដឹកនាំមន្ទីរជាស្ត្រីបានចូលរួមក្នុងសមាសភាពគណៈកម្មាធិការ និងក្រុមការងារយេនឌ័រ នៅក្រសួង និងខេត្ត ជាពិសេសនៅក្នុងសមាសភាពគណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារ ដែលបានរៀបចំប្រជុំជារៀងរាល់ខែ និងមានរបាយការណ៍ដោយទៀងទាត់ទៅក្រសួង និងរដ្ឋបាលខេត្ត។ មន្ទីរលើកទឹកចិត្ត ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ដោយផ្តល់អាទិភាពនានា តាមគោលការណ៍សមធម៌។

**២.ការងារអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍**

ការិយាល័យផ្លូវជនបទបានរៀបចំបញ្ជីសារពើភ័ណ្ឌ និងទិន្នន័យផ្លូវជនបទ ចំនួន ៥៧០ខ្សែ មានប្រវែងសរុប ១ ៨០៧.០៤១ គីឡូម៉ែត្រ។ បានសាងសង់ទីទួលសុវត្ថិភាពចំនួន ០១កន្លែង និងបង្គន់អនាម័យ ចំនួន ០៤បន្ទប់ ស្ថិតនៅឃុំកោះរកា ស្រុកកំពង់សៀម។ បានអភិវឌ្ឍន៍ផ្លូវជនបទពីផ្លូវក្រាលក្រួសក្រហម មកជាផ្លូវក្រាលកៅស៊ូពីរជាន់ ប្រវែងសរុប ១២២ ៩០០ ម៉ែត្រ ផ្លូវបេតុងប្រវែង ៣០ ២៤៨ ម៉ែត្រ សាងសង់លូប្រអប់ចំនួន ១៦ ដែលអនុវត្តដោយ **គម្រោងកែលម្អផ្លូវជនបទជំហានទីIII ADB (RRIP-III) និងគម្រោងគ្រប់គ្រងគ្រោះមហន្តរាយកម្ពុជា និងអាស៊ីអាគ្នេយ៍**។ ការិយាល័យផ្លូវជនបទ និងមន្ទីរបានថែទាំខួបផ្លូវជនបទ និងសំណង់សិល្បការ្យ ចំនួន២ខ្សែ ប្រវែង ១៨ ១០០ម៉ែត្រ និងថែទាំជាប្រចាំចំនួន ១៦ខ្សែ ប្រវែង ១១៨ ៨៦០ម៉ែត្រ។

**៣.ការងារកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ**

ការិយាល័យផ្គត់ផ្គង់ទឹកជនបទ បានសាងសង់អណ្តូងស្នប់អាហ្វ្រីដេសចំនួន ១៥អណ្តូង ក្នុងស្រុកបាធាយ ស្រុកស្ទឹងត្រង់ ស្រុកកំពង់សៀម និងស្រុកកោះសូទិន បានស្តារប្រឡាយសហគមន៍ចំនួន ០១ខ្សែ ប្រវែង ៣ ៥០០ ម៉ែត្រ (៤មx២មx១ម) នៅឃុំសំពងជ័យ ស្រុកជើងព្រៃ។

នៅពេលដែលចុះទៅត្រួតពិនិត្យការងារខួងអណ្តូងជូនប្រជាពលរដ្ឋក្រុមការងារបានពន្យល់ណែនាំគាត់អំពីការប្រើប្រាស់ទឹកស្អាត និងការទុកដាក់ឱ្យបានត្រឹមត្រូវ ។

**-អត្រាគ្រប់ដណ្តប់ខ្នងផ្ទះដែលមានទឹកស្អាតប្រើប្រាស់ក្នុងខេត្តមានចំនួន ៩១% ។**

ការិយាល័យថែទាំសុខភាពជនបទ បានចុះប្រជុំផ្សព្វផ្សាយការងារអនាម័យ និងជំរុញប្រជាពលរដ្ឋឱ្យសាងសង់ និងប្រើប្រាស់បង្គន់អនាម័យ ដើម្បីកុំឱ្យប៉ះពាល់ដល់សុខភាព និងមានសុវត្ថិភាពក្នុងគ្រួសារ ហើយនិងមានភាពថ្លៃថ្នូរក្នុងសង្គមជាតិ។ ក្រុមការងារមន្ទីរសហការជាមួយរដ្ឋបាលក្រុង/ស្រុក ឃុំ/សង្កាត់ និងភូមិ បានចុះស្រង់ទិន្នន័យបង្គន់តាមភូមិទាំងអស់ក្នុងខេត្តទាំង ៩១៦ ភូមិក្នុងមួយឆ្នាំ ២ដង និងរៀបចំចងក្រងជាឯកសារ និងបានបញ្ចូលទិន្នន័យក្នុងប្រព័ន្ធ MIS។ បានចុះប្រជុំជាប្រចាំលើការងារលើកកម្ពស់ការផ្លាស់ប្តូរទម្លាប់រស់នៅឱ្យមានការរស់នៅស្អាត និងមានអនាម័យនៅជនបទរស់នៅមានបរិស្ថានបរិសុទ្ធ អនាម័យខ្លួនប្រាណ អនាម័យលំនៅដ្ឋាន និងអនាម័យចំណីអាហារ ដើម្បីគ្រួសារមានសុខភាពល្អ។

ដោយមានការជួយគាំទ្រ និងការផ្តល់អនុសាសន៍ល្អៗ **ពីឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្ត** និងរដ្ឋបាលខេត្ត ក្រុមការងារបច្ចេកទេសវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទខេត្ត (PWG ) បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាសចំនួន ០៤ដង និងរៀបចំកិច្ចប្រជុំលេខាធិការនៃក្រុមការងារ បច្ចេកទេសវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទខេត្ត (PWG ) ដោយទៀងទាត់ នឹងមានប្រសិទ្ធិភាព។ ក្រុមការងារនេះបានរៀបចំវគ្គបណ្តុះបណ្តាលជូនដល់រដ្ឋបាលក្រុង/ស្រុក ឃុំ/សង្កាត់ ស្តីពីការប្រមូលទិន្នន័យ និងការផ្ទៀងផ្ទាត់ទិន្នន័យវិស័យទឹកស្អាតនិងអនាម័យជនបទ និងរៀបចំប្រជុំពិគ្រោះយោបល់អំពីរៀបចំផែនការសកម្មភាពវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទតាម ក្រុង/ស្រុក ទាំង១០ ក្នុង

ខេត្ត ដោយមានការចូលរួមពីគ្រប់តំណាងមន្ទីរ អង្គភាពពាក់ព័ន្ធក្នុងខេត្ត និងរដ្ឋបាលក្រុង/ស្រុក ឃុំ/សង្កាត់ និងអង្គការក្រៅរដ្ឋាភិបាលជាដៃគូនៅក្នុងខេត្ត ។

**-អត្រាគ្រប់ដណ្តប់ខ្នងផ្ទះដែលមានបង្គន់អនាម័យប្រើប្រាស់ក្នុងខេត្តមានចំនួន ៨៥%។**

-ចំនួនភូមិដែលឈប់បន្ទោរបង់ពាសវាលពាសកាល(ODF) មានចំនួន ១៥០ភូមិ និងចំនួនឃុំដែលបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាល (ODF) ចំនួន៣ឃុំ និង ៣សង្កាត់។ ក្នុងឆ្នាំ២០២២នេះ មន្ទីរបានជួយផ្តល់សម្ភារសាងសង់បង្គន់អនាម័យជនបទជូនប្រជាពលរដ្ឋចំនួន ៥០ខ្នងផ្ទះ ដោយប្រើប្រាស់ថវិកាកម្មវិធីឆ្នាំ២០២២។

**៤.ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ**

ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ និងក្រុមការងារឥណទានក្រសួងអភិវឌ្ឍន៍ជនបទ នៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្តមានគម្រោងឥណទានចំនួន២ ដែលបាននឹងកំពុងដំណើរការក្នុងខេត្តកំពង់ចាម រួមមានៈ ទី១. **គម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទ** នៅក្នុងស្រុក ៤គោលដៅ ៩ឃុំ ២៣ភូមិ និងអតិថិជនចំនួន ២៧៨ក្រុម សរុប ៤៧០នាក់ ស្រី ៣៤៣នាក់ ដែលបានទឹកប្រាក់ឱ្យខ្ចីចំនួន ១ ៤៥៣ ៣០០ ០០០ រៀល។ ទី២. **គម្រោងឥណទានមន្ត្រីរាជការ** នៅក្នុងឃុំគោលដៅចំនួន ១២ឃុំ ចំនួន ១៣ភូមិ និងអតិថិជន ចំនួន១៦ក្រុម សរុប ១៦នាក់ ស្រី ៥នាក់ ដែលបានទឹកប្រាក់ឲ្យខ្ចីចំនួន ៣២ ០០០ ០០០ រៀល។ គម្រោងឥណទានទាំង២ ខាងលើមានការប្រាក់ទាបសមស្រប និងជួយលើកស្ទួយជីវភាពប្រជាពលរដ្ឋ និងបង្កើតការងារ និងមុខរបរ។ ទន្ទឹមនឹងនេះដែរ មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋានរបស់មន្ទីរបានបណ្តុះបណ្តាលជំនាញនានា ចំនួន ៧វគ្គ ដែលមានសិក្ខាកាមចូលរួមសរុបចំនួន ១៤៨នាក់ ស្រី ៦០នាក់ ដែលរួមមានៈ ការបណ្តុះបណ្តាលកុំព្យូទ័រដល់សិស្ស និស្សិត ចំនួន ២វគ្គ ភាសាអង់គ្លេស ចំនួន ១វគ្គ បណ្តុះបណ្តាលកែសម្ផស្ស ចំនួន ១វគ្គ បណ្តុះបណ្តាលការចិញ្ចឹមមាន់ ចំនួន ១វគ្គ បណ្តុះបណ្តាលធ្វើជីកំប៉ុស្តិ៍ ចំនួន ១វគ្គ និងជួសជុលអណ្តូងស្នប់ចំនួន ១វគ្គ។ សិក្ខាកាម សិស្ស និស្សិត ដែលបានចូលរួមវគ្គបណ្តុះបណ្តាលទាំងអស់មាន ចំណេះដឹង និងការអនុវត្តជំនាញដែលបានបណ្តុះបណ្តាលយកទៅប្រកបរបររកប្រាក់ចំណូល បង្កើនជីវភាពរស់នៅបានប្រសើរឡើង។

**៥.សមិទ្ធផលនៃការអនុវត្តគម្រោង និងកម្មវិធីសហប្រតិបត្តិការ**

ក្នុងឆ្នាំ ២០២២នេះ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម បានសហការជាមួយ **អង្គការលោកខាងលិចជួបលោកខាងកើត** EMW (East Meets West) ដោយផ្តល់ថវិកា និងការគាំទ្រវាល់កិច្ចប្រជុំ និងការបណ្តុះបណ្តាល ដែលបានរៀបចំឡើងដោយក្រុមការងារបច្ចេកទេសវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទខេត្ត (PWG )។ សហការជាមួយ **អង្គការទឹកស្អាត១០០១** បានចុះតាមដាន និងត្រួតពិនិត្យការអនុវត្តការផ្គត់ផ្គង់ទឹកស្អាតនៅស្ថានីយ៍ផលិតទឹកពីដុង ២០លីត្រ ចំនួន ២៩កន្លែង និងអង្គការ world hope international សាងសង់បង្គន់អនាម័យ និងអប់រំសុខភាពអនាម័យ និងផ្គត់ផ្គង់ទឹកស្អាត នៅឃុំអូរស្វាយ និងស្រុកកំពង់សៀម។

II. **បញ្ហាប្រឈម**

- ការយល់ដឹងរបស់ប្រជាពលរដ្ឋនៅមានកម្រិត
- អង្គការដៃគូសហការវិស័យទឹកស្អាត និងអនាម័យជនបទមានចំនួនតិច ថវិកាស្ដួចស្ដើង
- គ្មានកញ្ចប់ថវិកាសម្រាប់ចុះប្រមូលទិន្នន័យបង្គន់អនាម័យនិងការវាយតម្លៃភូមិ និងឃុំ ដែលបញ្ឈប់បន្ទោបង់ពាសវាលពាសកាល
- ខ្វះមធ្យោបាយ និងប្រេងឥន្ធនៈ ធ្វើដំណើរសម្រាប់ចុះមូលដ្ឋាន
- ថវិកាសម្រាប់ចុះអនុវត្តសកម្មភាពការងារនៅមានកម្រិត។

III. **ទិសដៅការងារឆ្នាំ ២០២៣**

**១.ការពង្រឹងស្ថាប័ន និងកសាងសមត្ថភាព**

- **ការងាររដ្ឋបាល និងបុគ្គលិក**

នៅឆ្នាំ២០២៣ ខាងមុននេះ មន្ទីរមានផែនការពង្រឹងវិន័យការងារដល់មន្ត្រីរាជការដោយអនុវត្ត តាមសហលក្ខន្តិកៈមន្ត្រីរាជការ អនុក្រិត្យ សារាចរ សេចក្ដីណែនាំនានា របស់រាជរដ្ឋាភិបាល ពិសេស ក្រសួងមុខងារសាធារណៈ និងក្រសួងអភិវឌ្ឍន៍ជនបទ។ លើកទឹកចិត្តមន្ត្រីរាជការឱ្យខិតខំរៀនសូត្រនូវ បច្ចេកទេស ឌីជីថល ប្រព័ន្ធអនឡាញ កុំព្យូទ័រ និងការងារជំនាញផ្សេងៗ រួមទាំងការងាររដ្ឋបាល និង គ្រប់គ្រងផងដែរ។ រៀបចំរបាយការណ៍នៃចលនាបុគ្គលិក ប្រចាំខែ ត្រីមាស ឆ្នាំ ជូនក្រសួងអភិវឌ្ឍន៍ ជនបទ ក្រសួងមុខងារសាធារណៈ និងរដ្ឋបាលខេត្ត។ រៀបចំរបាយការណ៍រីកចម្រើនប្រចាំខែ ត្រីមាស ឆមាស ឆ្នាំ របស់មន្ទីរជូនក្រសួង និងរដ្ឋបាលខេត្តឲ្យបានទាន់ពេលវេលា។ រៀបចំសៀវភៅលេខចេញ ចូល និងទុកដាក់ឯកសារនានាឱ្យមានសណ្ដាប់ធ្នាប់ និងត្រឹមត្រូវ។ រៀបចំសោភ័ណ្ឌភាព និងអនាម័យក្នុង និងខាងក្រៅបរិវេណមន្ទីរ។

- **ការងារផែនការ**

ការិយាល័យផែនការ និងស្ថិតិ នៃមន្ទីរអភិវឌ្ឍន៍ជនបទ នៅឆ្នាំ២០២៣ ខាងមុខនេះ គឺតាម ដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការ ៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំ រំកិលរបស់មន្ទីរ ឆ្នាំ ២០២៣-២០២៥។ ទន្ទឹមនឹងនេះតាមដានការអនុវត្តគម្រោងថវិការបស់មន្ទីរប្រចាំឆ្នាំ២០២៣។ បន្ត រៀបចំចងក្រងទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ច តាមភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ក្នុងខេត្ត និងធ្វើបច្ចុប្បន្ន ភាពផងដែរ តាមប្រព័ន្ធអនឡាញ។ រៀបចំផែនការយុទ្ធសាស្ត្រថវិកាប្រចាំឆ្នាំ២០២៤-២០២៦ និង ផែនការថវិកាប្រចាំឆ្នាំ ២០២៤។ រៀបចំពង្រឹងសមត្ថភាពមន្ត្រីលើការងារផែនការ និងស្ថិតិ ដើម្បីឱ្យការ បំពេញការងារឱ្យកាន់តែមានប្រសិទ្ធភាពឡើង។

- **ការងារផ្គត់ផ្គង់ និងហិរញ្ញវត្ថុ**

នៅក្នុងឆ្នាំ២០២៣ មន្ទីរគ្រោងចំណាយឥណទានសរុបចំនួន 1.879.600.000 ៛ ក្នុងនោះ រួមមាន៖

- ជំពូក៦០ (ការទិញ) មានឥណទានសរុប **187.200.000 ៛**
- ជំពូក៦១ (សេវាកម្ម) មានឥណទានសរុប **865.700.000 ៛**

- ជំពូក៦៤ (បន្ទុកបុគ្គលិក) មានឥណទានសរុប 825.000.000 ៛
- ជំពូក៦៣ (ពន្ធ និងអាករ) មានឥណទានសរុប 1.700.000 ៛

**-ការងារសវនកម្ម**

រៀបចំសំណុំបែបបទ រៀបចំទុកដាក់ឯកសារឱ្យបានត្រឹមត្រូវតាមលំដាប់លំដោយ តាមនិតិវិធីដែលបានណែនាំទាំងផ្នែករដ្ឋបាល គណនេយ្យ ហិរញ្ញវត្ថុ និងថវិកា រួមទាំងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងបញ្ជីសារពើភ័ណ្ឌ។ បន្តសហការជាមួយក្រុមការងារសវនកម្មជាតិ សវនកម្មផ្ទៃក្នុងរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្រុមអធិការកិច្ចក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមអធិការកិច្ចក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច។

**-ការងារយេនឌ័រ**

បន្តការយកចិត្តទុកដាក់ និងលើកទឹកចិត្តដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីរាជការជាស្ត្រី ដោយផ្តល់អាទិភាពជាងបុរស ដោយអនុវត្តតាមគោលការណ៍សមធម៌ និងក្នុងចែងក្នុងច្បាប់។

**-ការងារជនពិការ**

រៀបចំថែទាំ និងយកចិត្តទុកដាក់មន្ត្រីរាជការជាជនពិការចំនួន ០១នាក់ ប្រុស ០១នាក់ ដែលជំងឺសរសៃប្រសាទពុំរ៉ៃ និងស្នើសុំទៅក្រសួងដាក់ឱ្យបាត់បង់សមត្ថភាពពលកម្ម ឬដាក់ឱ្យចូលនិវត្តន៍មុនកាលកំណត់

**២.ការងារអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍**

បន្តរៀបចំបញ្ជីសារពើភ័ណ្ឌទិន្នន័យផ្លូវជនបទ និងធ្វើបច្ចុប្បន្នភាព និងស្រង់ទិន្នន័យផ្លូវថ្មីដែលនៅសល់ និងរៀបចំចងក្រងជាឯកសារទាំង soft និង Hard Copy។

- បន្តការងាររាប់ចំនួនចរាចរណ៍ ចំនួន ១០ខ្សែទៀត
- បន្តការងារសាងសង់ទីទួលសុវត្ថិភាព ០១កន្លែង
- បន្តការងារថែទាំផ្លូវជនបទជាលក្ខណៈខួប និងជាប្រចាំ
- បន្តការងារជួសជុលផ្លូវជនបទ និងសំណង់សិល្បការ ដែលខូចខាត។

**៣.ការងារកែលម្អលក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទ**

**-ការងារផ្គត់ផ្គង់ទឹកស្អាត**

- បន្តសាងសង់អណ្តូងស្នប់អាហ្វ្រីដេស ចំនួន ១៥អណ្តូង ក្នុងស្រុកជើងព្រៃ ស្រុកកោះសូទិន ស្រុកចំការលើ និងស្រុកកំពង់សៀម។
- បន្តសាងសង់អណ្តូងស្នប់ ជីកប្រឡាយ ជីកស្រះ។
- បន្តជួសជុលអណ្តូងស្នប់អាហ្វ្រីដេស
- បន្តស្តារប្រឡាយ ២ខ្សែ ប្រវែង ៣ ០០០ ម៉ែត្រ (៤មx២មx១ម) និងស្រុកកំពង់សៀម និងស្រុកព្រៃឈរ។
- ជួយជួសជុលអណ្តូងស្នប់ និងអណ្តូងលូ ដែលរងគ្រោះដោយសារគ្រោះធម្មជាតិ
- ការងារបណ្តុះបណ្តាលបច្ចេកទេសថែទាំ និងជួសជុលអណ្តូងទឹកនៅជនបទ ដល់សហគមន៍ប្រើប្រាស់ទឹក

- បន្តបើកវគ្គបណ្តុះបណ្តាលជួសជុល និងថែទាំអណ្តូងស្នប់
- បន្តចុះទៅត្រួតពិនិត្យការងារខួងអណ្តូងជូនប្រជាពលរដ្ឋ និងបានពន្យល់ណែនាំគាត់អំពីការប្រើប្រាស់ទឹកស្អាត និងការទុកដាក់ឱ្យបានត្រឹមត្រូវ។

**-ការងារថែទាំសុខភាពជនបទ**

- បន្តចុះស្រង់ទិន្នន័យបង្គន់អនាម័យនិងធ្វើបច្ចុប្បន្នភាពទិន្នន័យបង្គន់តាមភូមិនិងបញ្ចូលតាមប្រព័ន្ធអនឡាញ MIS
- ការងារលើកកម្ពស់ការផ្លាស់ប្តូរទម្លាប់ឱ្យមានការរស់នៅស្អាត និងមានអនាម័យនៅជនបទ
- ការងារអប់រំជំងឺឆ្លង និងសុខភាពផ្លូវភេទ
- បន្តផ្សព្វផ្សាយជូនប្រជាពលរដ្ឋតាមភូមិ ឃុំ/សង្កាត់ ក្រុង/ស្រុក និងឃុំ/សង្កាត់ ក្រុង/ស្រុក ដែលបញ្ឈប់បន្ទោរបង់ពាសវាលពាសកាល (ODF) ឱ្យបានសមស្រប ត្រឹមត្រូវតាមគោលការណ៍ និងនីតិវិធីណែនាំរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ធ្វើយ៉ាងណាឱ្យសម្រេចតាមផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលគឺ ចុងឆ្នាំ២០២៣ អត្រាគ្របដណ្តប់ខ្នងផ្ទះ ដែលបានបង្គន់អនាម័យប្រើប្រាស់ទូទាំងខេត្ត ចំនួន ៩០% និងចុងឆ្នាំ២០២៥ សម្រេចបាន ១០០%

**៤.ពិពិធកម្មសកម្មភាពសេដ្ឋកិច្ចជនបទ**

- បន្តការផ្តល់ឥណទាន ២ប្រភេទ ជូនប្រជាពលរដ្ឋ និងមន្ត្រីរាជការ នៅតាមស្រុក ឃុំ ភូមិគោលដៅដោយការប្រាក់សមស្រប ដើម្បីជួយសម្រួលជីវភាពរស់នៅដល់ពួកគាត់
- បន្តសិក្សាពីបច្ចេកទេសចិញ្ចឹមសត្វ ដាំដំណាំកសិកម្ម ធ្វើជីកំប៉ុស្តិ៍ និងបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈដល់សិស្ស និស្សិត ប្រជាពលរដ្ឋនូវជំនាញ កុំព្យូទ័រ ភាសាអង់គ្លេស អ៊ុតសក់ ជួសជុលម៉ូតូ។ ដើម្បីមានជំនាញ និងបង្កើតមុខរបរកាត់បន្ថយការចំណាកស្រុករួមចំណែកកាត់បន្ថយភាពក្រីក្រ។

**៥.សមិទ្ធផលនៃការអនុវត្តគម្រោង និងកម្មវិធីសហប្រតិបត្តិការ**

- បន្តសហប្រតិបត្តិការជាមួយអង្គការជាដៃគូ និងសប្បុរសជននានាទាំងនៅក្នុង និងក្រៅប្រទេសដើម្បីកៀងគរជំនួយយកមកអភិវឌ្ឍន៍ក្នុងខេត្ត ពិសេសទីជនបទដាច់ស្រយាល។

## សេចក្តីសន្និដ្ឋាន

យោងតាមរបាយការណ៍អនុវត្តន៍គោលនយោបាយយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍បានបង្ហាញឱ្យឃើញថាដើម្បីអនុវត្តន៍ផែនការអភិវឌ្ឍន៍ជនបទបានសម្រេចលុះត្រាតែយើង បានអនុវត្តនូវសកម្មភាពដូចខាងក្រោមនេះ៖

- តាមដានធ្វើបច្ចុប្បន្នភាព និងចុះពង្រឹងការបណ្តុះបណ្តាលអភិវឌ្ឍន៍សមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) ដែលត្រូវបានចំណាត់ថ្នាក់ជាអាទិភាព នៅក្នុងគោលនយោបាយអភិវឌ្ឍន៍ជនបទ។

- ជំរុញការសាងសង់ និងជួសជុល នូវហេដ្ឋារចនាសម្ព័ន្ធជនបទ ដូចជា សំណង់ធារាសាស្ត្រ ផ្លូវជនបទ និងសំណង់សិល្បការ្យផ្សេងៗ។
- ពង្រឹងសមត្ថភាពមន្ត្រីរាជការ ឱ្យមានចំណេះដឹង មុខជំនាញ ក្នុងការបំពេញការងារជូនជាតិមាតុភូមិឱ្យមានប្រសិទ្ធិភាពខ្ពស់ ពិសេសបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋបានល្អ។

ដោយអនុវត្តន៍គោលនយោបាយយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍ជនបទរបស់មន្ទីរបានបង្ហាញឱ្យឃើញថា៖ ខេត្តកំពង់ចាម ទទួលបានការអភិវឌ្ឍដូចជា ស្ពាន និងផ្លូវលំជនបទ ខ្វាត់ខ្វែងសម្រាប់ប្រជាពលរដ្ឋធ្វើចរាចរណ៍ក្នុងការដឹកនាំកសិផលដែលជាកត្តាធ្វើឱ្យប្រជាពលរដ្ឋទៅកាន់តែជិតរវាងជនបទ និងទីក្រុងធ្វើឱ្យប្រជាជនមានប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតសម្រាប់ប្រើប្រាស់ ជាពិសេសធ្វើឱ្យការយល់ដឹងពីសុខភាព និងអនាម័យតាមរយៈការអប់រំ ផ្សព្វផ្សាយ និងប្រើប្រាស់បង្គន់អនាម័យ។

សរុបសេចក្តីមក យើងឃើញថា ការអនុវត្តន៍គោលនយោបាយ និងផែនការអភិវឌ្ឍន៍ជនបទបានចូលរួមអនុវត្តន៍ឱ្យបានជោគជ័យនូវយុទ្ធសាស្ត្រ **ចតុកោណដំណាក់កាលទី៤ អាណត្តិទី៦** និងគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈរបស់រាជរដ្ឋាភិបាលក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប្រកប ដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីបម្រើប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង សំដៅលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋតាមរយៈការផ្តល់ហេដ្ឋារចនាសម្ព័ន្ធ ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ធ្វើឱ្យប្រជាពលរដ្ឋមានល័ក្ខខ័ណ្ឌល្អប្រសើរក្នុងជីវភាពរស់នៅដើម្បីរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។